# សម្ភាសន៍ជាមួយឈ្មោះ ប៊ីន ណាន់ ភេទស្រី អាយុ៧៨ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហម ៖ អ្នកទោសនៅភ្នំទ្រយោង

ស្រុកកំណើតនៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១

សម្ភាសន៍ដោយ ៖ ឡុង ដានី និង វ៉ាន់ថាន់ ពៅដារ៉ា

០០៖៣២៖១៥

២២ទំព័រ

ដានី ៖ អ៊ីចឹងជំបូងខ្ញុំសុំស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះពេញឈ្មោះអីដែរ?

ណាន់ ៖ ខ្ញុំឈ្មោះ ណាន់ៗ ជីតាខ្ញុំឈ្មោះ ប៊ីនៗ

ដានី ៖ ឈ្មោះអីគេ?

ណាន់ ៖ ជីតា ជីតាឈ្មោះ ប៊ីន ប៊ីន ណាន់ៗ

ដានី ៖ ប៊ីន ក៏ប៊ិន?

ណាន់ ៖ ប៊ីន ចាស! ប៊ីនៗ

ដារ៉ា ៖ ប៊ីន ណាន់?

ណាន់ ៖ ចាស!

ដានី ៖ ប៊ីន ណាន់ៗ បាទ! អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ណាន់ ៖ ខ្ញុំសព្វថ្ងៃអាយុ៧៨ៗ

ដានី ៖ អាយុ៧៨ៗ បាទ! ចុះប្តីអ៊ំគាត់ឈ្មោះអីដែរ?

ណាន់ ៖ ឈ្មោះ សែៗ

ដានី ៖ ឈ្មោះអី ដែរ?

ណាន់ ៖ ឈ្មោះ ឌឿ សែៗ

ដានី ៖ ឌឿ សែ អ្ហី?

ណាន់ ៖ ចាស!

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ណាន់ ៖ គាត់ស្លាប់តាំងពីយូរណាស់ហើយ ។

ដានី ៖ គាត់ស្លាប់តាំងពីកាល?

ណាន់ ៖ កាលសម័យនោះឯង ។

ដានី ៖ ស្លាប់ក្នុងសម័យ ប៉ុល ពត?

ណាន់ ៖ ចាស!

ដានី ៖ ឆ្នាំណា គាត់ស្លាប់ឆ្នាំណា?

ណាន់ ៖ មិនដឹងឆ្នាំណាទេ ដឹងតែប៉ុល ពត ។

ដានី ៖ ចុះអ៊ីមានកូនចៅប៉ុន្មាននាក់ដែរ?

ណាន់ ៖ មានតែមួយហ្នឹងឯង ។

ដានី ៖ ឈ្មោះអីដែរកូនមួយ?

ណាន់ ៖ កូនឈ្មោះ ខេង ។ កូនប្រុសអម្បាញ់មិញ ។

ដានី ៖ កូនប្រុសម្នាក់ឈ្មោះ ខេង?

ណាន់ ៖ ចាស!

ដារ៉ា ៖ កូនប្រុសហ្នឹងជាមួយនឹងគ្រួសារអ៊ំឈ្មោះ សែ ហ្នឹង?

ណាន់ ៖ ចាស ៗ!

ដានី ៖ គាត់ឈ្មោះអីគេ?

ណាន់ ៖ ឈ្មោះ ខេង, រិន ខេង ។

ដានី ៖ រិន ខេង វិញ?

ណាន់ ៖ ចាស!

ដានី ៖ ចុះអ៊ីអ្នកស្រុកកំណើតកើតជានៅឯណាដែរ?

ណាន់ ៖ នៅភូមិកណ្តាលនេះឯង ព្រះនេត្រព្រះ ភូមិកណ្តាល ។

ដារ៉ា ៖ ភូមិកណ្តាល ឃុំព្រះនេត្រព្រះ?

ណាន់ ៖ ចាស!

ដានី ៖ ឃុំព្រះនេត្រព្រះអ្ហ៎?

ណាន់ ៖ ចាស! ស្រុកព្រះនេត្រព្រះ ។

ដានី ៖ ស្រុកព្រះនេត្រព្រះ ខេត្តអីគេ? បាទ! ហើយឥឡូវសព្វថ្ងៃនេះអ៊ីរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

ណាន់ ៖ ស្រុកនេះឯង ស្រុកព្រះនេត្រព្រះនេះឯង ភូមិអាករ កំណើតកើតនេះឯង។

ដានី ៖ នៅភូមិកណ្តាលដែរ?

ណាន់ ៖ ចាស!

ដានី ៖ ចុះអ៊ំ ឪពុកអ៊ីគាត់ឈ្មោះអីដែរ?

ណាន់ ៖ ឪពុកខ្ញុំឈ្មោះ ដាត់ ម្តាយខ្ញុំឈ្មោះ ឃុត។

ដានី ៖ ឪពុកឈ្មោះ ដាត់ អី?

ណាន់ ៖ ចាស!

ដារ៉ា ៖ ម្តាយឈ្មោះ ឃុត។

ដានី ៖ ម្តាយឈ្មោះ ឃុត?

ណាន់ ៖ ចាស!

ដានី ៖ សព្វថ្ងៃគាត់ទាំងពីរនាក់ខូចអស់ហើយអ្ហី?

ណាន់ ៖ ខូចអស់ហើយ ខូចយូរណាស់ហើយតាំងពីសង្គម។

ដានី ៖ ខូចតាំងពីសង្គម?

ណាន់ ៖ ចាស! គាត់ចាស់ពីសង្គមជាមួយខ្ញុំ។

ដានី ៖ ចុះអ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

ណាន់ ៖ បងប្អូនខ្ញុំមានប្រាំនាក់។

ដានី ៖ បងប្អូនប្រាំនាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ណាន់ ៖ ប្រុសមួយ ប៉ុន្តែស្រីមួយងាប់ហើយ។ ស្រីប្រាំ ប្រុសមួយ។

ដានី ៖ ស្រីប្រាំ ប្រុសមួយ ប្រាំមួយនាក់?

ណាន់ ៖ ចាស! ប្រាំមួយ ប៉ុន្តែងាប់មួយហើយ។

ដានី ៖ ស្លាប់ម្នាក់ហើយ ប៉ុន្តែស្លាប់ពីកាលណាដែរម្នាក់?

ណាន់ ៖ ស្លាប់ឆ្នាំទៅ។

ដានី ៖ ស្លាប់ឆ្នាំទៅ។ ចុះអ៊ំកូនទីប៉ុន្មាន?

ណាន់ ៖ ខ្ញុំណោះ?

ដានី ៖ បាទ!

ណាន់ :	នេះៗកូនទីមួយ រាប់ពីមុនគ្មានទេ កូនស្លាប់អស់ ។

ដានី :	តែអ៊ីៗបងក្នុងចំណោមបងប្អូនប្រាំមួយហ្នឹង?

ណាន់ :	ខ្ញុំកូនបងបង្អស់ ។

ដានី :	បងប្អូនទីមួយ?

ណាន់ :	ចាស! ទីមួយ ស្តាប់ប្រសាសន៍មិនបានទេខ្ញុំនោះ ។

ដានី :	ចុះអ៊ីកាលពីក្មេងៗ អ៊ីបានរៀនសូត្រអីទៅដល់ណាដែរ?

ណាន់ :	មិនដែលបានរៀនអីទេ មិនដឹងអីទេ ។

ដានី :	អត់ដែលបានចូលសាលាសោះ?

ណាន់ :	ទេ ។

ដានី :	ចុះអ៊ីអត់ចូលសាលាអីទេ ចុះកាលនៅក្មេងៗធ្វើអីខ្លះទៅ?

ណាន់ :	គ្មានធ្វើអ្វីទេ ឪពុកខ្ញុំអ្នកស្រែ គិតតែច្រូត ។

ដានី :	អ៊ីទៅជួយធ្វើស្រែ ។

ណាន់ :	ចាស! ជួយធ្វើស្រែឪពុកហ្នឹងឯង ។

ដានី :	ធ្វើស្រែឪពុកម្តាយ?

ណាន់ :	ចាស!

ដានី :	ចុះអ៊ីរៀបការឆ្នាំណា?

ណាន់ :	អូ! មិនដឹងទេ បើខ្ញុំឆ្នាំ ច ។

ដានី :	អ៊ីឆ្នាំ ច ហ្អី អីចឹង អ៊ីចាំរៀបការឆ្នាំណាដែរ?

ណាន់ :	មិនចាំទេ ។

ដានី :	អ៊ីការបានប៉ុន្មានឆ្នាំបានមានកូន?

ណាន់ :	អូ! មិនដឹងបានប៉ុន្មានទេ មិនបានដាគិតគូរទេ ក្មេងណោះ នៅក្មេងមិនបានគិតគូរអីទេ ។

ដានី :	បាទ! ចុះកូនលោកអ៊ីគាត់កើតឆ្នាំអីដែរ?

ណាន់ :	កូនខ្ញុំ កូនងាប់អស់អីចេះ កូនងាប់អស់ កូនទីមួយនោះហ្នឹងឆ្នាំម្សាញ់ កូនទីមួយឆ្នាំម្សាញ់ កូនទីពីរដូចមិនដឹងឆ្នាំអីទេ បើងាប់អីចឹង មិនបានដាគិតគូរអីទេ ។

ដានី :	ប៉ុន្តែអ៊ីដូចថាអ៊ីរៀបការប៉ុន្មានឆ្នាំបានមានកូនទីមួយ?

ណាន់ :	មិនបានយូរទេ មួយឆ្នាំជាង ។

ដានី :	មួយឆ្នាំជាងអី?

ណាន់ ៖ ចាស!

ដានី ៖ អីចឹងដល់ពេលបានមួយឆ្នាំជាង អីចឹងបានកើតកូនទីមួយឆ្នាំម្សាញ់?

ណាន់ ៖ ចាស! ។

ដារ៉ា ៖ ចុះអ៊ំមានកូន រាប់ទាំងស្លាប់ទាំងអីផងប៉ុន្មាននាក់ទៅអ៊ំ?

ណាន់ ៖ កូនខ្ញុំទាំងងាប់ទាំងអីឡើងប្រាំនាក់ ។

ដារ៉ា ៖ ប្រាំនាក់?

ណាន់ ៖ ងាប់អស់ ។

ដារ៉ា ៖ អីចឹងស្លាប់បួន?

ណាន់ ៖ ចាស!

ដារ៉ា ៖ ស្លាប់បួន អ៊ំណោះ?

ណាន់ ៖ ចាស!

ដារ៉ា ៖ ហើយនៅសល់តែមួយទេ សល់កូនប្រុសមួយ ។ ស្លាប់ហ្នឹងស្លាប់ក្នុងសម័យណា?

ណាន់ ៖ សម័យពីសង្គមហ្នឹង សម័យពីសង្គមផងក៏កាលពី ប៉ុល ពត ងាប់តែមួយទេ ។

ដារ៉ា ៖ កាលជំនាន់ ប៉ុល ពត ងាប់តែមួយទេ ។

ណាន់ ៖ ចាស!

ដារ៉ា ៖ ស្លាប់តែមួយទេ?

ណាន់ ៖ ចាស!

ដារ៉ា ៖ អីចឹងស្លាប់តាំងពីសម័យសង្គមហ្នឹងបី?

ណាន់ ៖ ចាស!

ខេង ៖ ស្លាប់ដោយសារ...?

ណាន់ ៖ មិនមែនទេ កូនងាំមកដូចថាវាឈឺវាជាន់អីទៅណា មិនមានពេទ្យមានអី ។

ដារ៉ា ៖ កាលហ្នឹងអត់ទាន់មានពេទ្យមានអីដូចសព្វថ្ងៃអ៊ំណា?

ណាន់ ៖ ចាស!

ដានី ៖ ចុះអ៊ំកាលពីអ៊ំរៀបការហើយ អ៊ំប្រកបមុខរបររកស៊ីធ្វើអីដែរ?

ណាន់ ៖ ធ្វើស្រែ បានប្ដីក៏ធ្វើស្រែប៉ុណ្ណោះឯង ។

ដានី ៖ ធ្វើស្រែនៅណា?

ណាន់ ៖ ធ្វើស្រែយើងតាមនេះឯង នេះហួសភ្នំនេះ ។

ដានី ៖ ចុះប្ដីអ៊ំអ្នកស្រុកកំណើតនៅឯណាដែរ?

ណាន់ ៖ ប្ដីខ្ញុំអ្នកស្រុកជាមួយគ្នានេះឯង។

ដានី ៖ នៅភូមិកណ្ដាលនេះ?

ណាន់ ៖ ចាស!

ដានី ៖ ការហើយយើងធ្វើស្រែ ធ្វើអីទៅ?

ណាន់ ៖ ចាស! គ្មានធ្វើរោងអីទេ។

ដានី ៖ បាទ! ផ្ទះអ៊ំនៅណាដែរ?

ណាន់ ៖ ផ្ទះនេះឯង។

ដានី ៖ ផ្ទះហ្នឹងម៉ងអ្ហ៎?

ណាន់ ៖ ផ្ទះឪពុកខ្ញុំខាងណោះ ផ្ទះខាងនេះប៉ុណ្ណោះ។

ដានី ៖ ប៉ុន្ដែអ៊ំនៅនេះ?

ណាន់ ៖ ចាស!ខ្ញុំបានប្ដីក៏ទិញដី ទិញដីពីម្ដុំនៅណោះ ដល់ជំនាន់ ប៉ុល ពតវិញបានខ្ញុំនៅអានេះ។

ដានី ៖ អីចឹងអ៊ំធ្វើស្រែបានប៉ុន្មានឆ្នាំទៅបានឈប់?

ណាន់ ៖ ធ្វើយូរណាស់ហើយ។

ដានី ៖ ខ្ញុំចង់មានន័យថាពេលដែលអ៊ំការហើយមិនធ្វើស្រែធ្វើចម្ការជាមួយប្ដីប្រពន្ធហ្អី?

ណាន់ ៖ ចាស!

ដានី ៖ ដល់ពេលក្រោយមក ពេលរដ្ឋប្រហារទម្លាក់សម្ដេចសម័យ លន់ នល់ ឆ្នាំ៧០រដ្ឋប្រហារ អ៊ំនៅធ្វើអីទៀតទៅ?

ណាន់ ៖ ធ្វើអី មានតែធ្វើស្រែ ដល់នេះទៅក៏គេកៀរ ក៏គេឲ្យទៅកើត ធ្វើស្រែប៉ុណ្ណឹងឯង។

ដានី ៖ ចុះកាលហ្នឹងប្ដីអ៊ំគាត់ធ្វើអី?

ណាន់ ៖ គ្មានធ្វើអីទេ អ្នកស្រែនេះឯង។

ដានី ៖ បាទ! គាត់ធ្វើស្រែរហូតដល់គេកៀរទៅ?

ណាន់ ៖ ចាស!

ដានី ៖ កៀរហ្នឹង កៀរឆ្នាំណា?

ណាន់ ៖ មិនដឹងឆ្នាំណាទេ មិនចាំទេ បើចាំតាំងកូននៅតូចណោះ មិនសូវចង់ចាំទេ។

ដានី ៖ ចុះឥឡូវដល់ពេលដែលប៉ុល ពតចូលឆ្នាំ៧៥ណា ដល់ពេលលន់ នល់ហើយទៅ ប៉ុល ពត ចូលមក ចូលមកហ្នឹងគេមិនទាន់កៀរ ឬក៏កៀរហើយ?

ណាន់ ៈ គេកៀរ មើលដល់គេចូលមក គេដេញអ្នកភូមិនេះឲ្យទៅនៅវាល ។

ដានី ៈ ឲ្យទៅនៅឯណាវិញ?

ណាន់ ៈ នៅក្នុងភ្នំកូនដំរីណោះ នោះភ្នំ ។

ដានី ៈ កាលណោះអ៊ំទៅជួបជុំគ្រួសារដែរ?

ណាន់ ៈ ចាស! ជួបជុំកូន ។

ដានី ៈ ប្តី?

ណាន់ ៈ ចាស! ទាំងអស់គ្នានេះឯង ។

ដាវ៉ា ៈ ចុះពួកដេញហ្នឹងស្លៀកពាក់អី ស្លៀកពាក់ខ្មៅហ្អីមីង?

ណាន់ ៈ ស្លៀកពាក់យើងធម្មតានេះឯង ។

ដាវ៉ា ៈ អត់ទេអាអ្នកមកដេញណា ដេញចេញពីភូមិហ្នឹង អាហ្នឹងពួក?

ណាន់ ៈ ស្លៀកពាក់អាវខ្មៅ ។

ដាវ៉ា ៈ អ៊ីចឹង?

ណាន់ ៈ ចាស!

ដាវ៉ា ៈ មានកាំភ្លើងមានអីដែរទេកាលហ្នឹង?

ណាន់ ៈ មានហើយគេស្ពាយ ។

ដាវ៉ា ៈ ហើយដល់ពេលជម្លៀសទៅ ជម្លៀសទៅភ្នំកូនដំរី?

ណាន់ ៈ ចាស! ដូចបានទៅ ។

ខេង ៈ ទៅស្រែះ ។

ណាន់ ៈ ទៅស្រែះ គេហៅស្រែះទៀត ។

ដាវ៉ា ៈ ចុះទៅដល់ភ្នំកូនដំរីហ្នឹងគេឲ្យធ្វើអី?

ណាន់ ៈ គ្មានធ្វើអីទេ ។

ដាវ៉ា ៈ ធ្វើស្រែធ្វើអី?

ណាន់ ៈ អត់ទាន់ធ្វើអីទេ ។

ដាវ៉ា ៈ អត់ទាន់ធ្វើអីទេ?

ណាន់ ៈ គេយកយើងទៅទុក ទៅនៅត្រេងត្រាងសិនហ្នឹងណា ។

ដាវ៉ា ៈ អ៊ីចឹងបានអី ហូបអី?

ណាន់ ៖ មានអីហូបដែលយើងមាន មានអីយើងដាក់រទេះ ដាក់អីជញ្ជូនហ្នឹងណាមានស្រូវ មានអង្ករទៅនៅ ។

ដារ៉ា ៖ ហើយបន្ទាប់មកបញ្ជូនទៅស្រែះ?

ណាន់ ៖ ចាស! បញ្ជូនទៅស្រែះ តាំងឡើងពីស្រែះមកនេះមកក៏គេឲ្យមកនៅស្រុកនេះឯង ប៉ុន្តែគេហៅប៉ោយព្រីង ។

ដារ៉ា ៖ ប៉ោយព្រីង?

ណាន់ ៖ ចាស!

ដារ៉ា ៖ អីចឹងទៅនៅស្រែះហ្នឹង យើងនៅក្នុងផ្ទះហូបបាយផ្ទះយើង ឬក៏ហូបរួម?

ណាន់ ៖ ហូបខ្លួនយើងហ្នឹងឯង ។

ដារ៉ា ៖ នៅស្រែះនេះអត់ទាន់ទេ?

ណាន់ ៖ ចាស!អាល័យតែច្រូត អាល័យតែអីនោះ ។

ដារ៉ា ៖ ចុះមានចេញទៅធ្វើការងារតាមស្រែតាមអីទេ?

ណាន់ ៖ ចាស!ធ្វើ ។

ដារ៉ា ៖ ទៅធ្វើធម្មតា?

ណាន់ ៖ ចាស! ធម្មតាណា គេឲ្យទៅច្រូត ។

ដារ៉ា ៖ ហើយហ្នឹងមានជាភូមិ ជាឃុំអីគេបែកទៅ?

ណាន់ ៖ ចាស!មាន ។

ដារ៉ា ៖ ចុះក្រោយមកពីស្រែះមក គេបញ្ជូន?

ណាន់ ៖ បញ្ជូនមកគេហៅ...

ដារ៉ា ៖ មកនៅប៉ោយព្រីង?

ណាន់ ៖ ចាស! ប៉ោយព្រីង ដល់នៅប៉ោយព្រីងរួចបានគេឲ្យមកស្ពានដុប គេហៅនៅពស់ពីរ ។

ដារ៉ា ៖ ពស់ពីរ?

ណាន់ ៖ ចាស! គេហៅនៅពស់ពីរនេះ ។

ដានី ៖ ប៉ុស្តិ៍ពីរ ឬពស់ពី?

ណាន់ ៖ ពស់ពី គេហៅមុខពស់ពីរ ។

ដារ៉ា ៖ អាសត្វពស់យើងនេះហ្នឹង?

ណាន់ ៖ ទេ! គេហៅហ្នឹងពស់ពីដីត្រង់ហ្នឹងណា ។

ដានី :	ប៉ុស្តិ៍ចាស់ ពស់ពីរ?

ណាន់ :	គេហៅពស់ពីរៗ ។

ដានី :	អូ! ពស់ពី ។

ណាន់ :	ចាស! គាត់ឆ្ការទុកណា មានគេធ្វើខ្ទមឲ្យ ឲ្យអណ្តែតខ្លួនយើងធ្វើខ្លួនយើងទៅណា ។

ដារ៉ា :	នៅជាក្រុមគ្រួសារ?

ណាន់ :	ចាស! ហ្នឹងក្រុមគ្រួសារយើងណា ។

ដារ៉ា :	កាលហ្នឹងអ៊ំមានកូនប៉ុន្មាននាក់?

ណាន់ :	ខ្ញុំមានតែមួយនេះឯង ។

ដារ៉ា :	អត់ទេ កាលកូននៅសម័យ?

ណាន់ :	ចាស! នៅតែមួយ ងាប់អស់ហើយ ងាប់តាំងពីសម័យនោះអស់ ខ្ញុំក៏ជាប់កូនមួយនេះឯង
មួយបដិវត្តន៍ ។

ដានី :	ចុះកាលហ្នឹងអ៊ំនៅជួបជុំគ្រួសារប្តីប្រពន្ធកូនចៅនៅជាមួយគ្នា?

ណាន់ :	ចាស!

ដានី :	ចុះអ៊ំនៅគេឲ្យធ្វើអី?

ណាន់ :	ខ្ញុំគេឲ្យប្រូត គេឲ្យធ្វើចម្ការ ។

ដានី :	ចុះអ៊ំប្រុសគេឲ្យធ្វើអីវិញ?

ណាន់ :	អ៊ំប្រុសលើកទំនប់ ។

ដានី :	គាត់លើកទំនប់?

ណាន់ :	ចាស!

ដានី :	គាត់ធ្វើអីខាងលើកទំនប់ហ្នឹង?

ណាន់ :	ពេលគេដេញឲ្យទៅលើក គាត់ទៅទៅណា គាត់ទៅលើកទំនប់តាមនេះ ។

ដានី :	ទំនប់អីគេ ទំនប់កំបោរស្រែះនេះ?

ណាន់ :	ចាស!

ដានី :	កាលហ្នឹងគាត់លើកជាមួយពីណា កាលហ្នឹងពីណាគេធ្វើប្រធានខាងទំនប់?

ណាន់ :	គេធ្វើប្រធានខ្ញុំមិនដឹងទេ ប្រធាននៅឆ្ងាយខ្ញុំមិនដែលដឹងទេ ។

ដានី :	គាត់អ្នកទៅលើក ឬគាត់អ្នកវាស់វែង?

ណាន់ :	មិនដឹងទេ ព្រោះគេចេញភារកិច្ច តែគេហៅ គាត់ទៅនឹងគេទៅ ។

ដានី ៖ បាទ! តែអ៊ំនៅធ្វើស្រែធ្វើចម្ការ?

ណាន់ ៖ ចាស! ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែ អត់លើកទំនប់ទេ?

ណាន់ ៖ អត់ ទេ! គេឲ្យខ្ញុំធ្វើចម្ការ ។

ដានី ៖ ធ្វើចម្ការ?

ណាន់ ៖ ចាស!

ដានី ៖ ធ្វើចម្ការធ្វើចម្ការអី?

ណាន់ ៖ ធ្វើចម្ការដាំដំឡូងដាំអីណា ។

ដានី ៖ ដាំដំឡូង ។ ចុះអ៊ំកាលហ្នឹងពុកថាប្រធានសហករណ៍ ប្រធានឃុំអីឈ្មោះអីទៅ?

ណាន់ ៖ ខ្ញុំមិនសូវដឹងទេប្រធាន ដឹងតែប្រធានដឹងប្រធានអីទេ ឃើញតែឈ្មោះ តាក្រុកៗ ។

ដានី ៖ តាក្រុក គាត់ប្រធានអី?

ណាន់ ៖ មិនដឹងប្រធានអីទេ ខ្ញុំមិនសូវដឹងទេ ខ្ញុំស្រីមិនសូវដឹងទេ ។

ដានី ៖ ចុះខាងគណៈស្រុកអី អ៊ំស្គាល់ទេ?

ណាន់ ៖ ទេមិនដែលស្គាល់គេទេ ។

ដានី ៖ ចុះអ៊ំកាលហ្នឹងអ៊ំធ្វើចម្ការ ដាំដំឡូង?

ណាន់ ៖ ចាស!

ដានី ៖ កាលហ្នឹងហូបចុកអីយ៉ាងម៉េចដែរ?

ណាន់ ៖ គ្មានអីទេ គេចែកបបរ ។

ដានី ៖ គេចែកបបរ?

ណាន់ ៖ ចាស! ដូចថាម្នាក់មួយវែកៗ ។

ដានី ៖ ហូបគ្រាន់ដែរអត់?

ណាន់ ៖ ទេ! មិនគ្រាន់ទេ យើងរកដំឡូងរកអីបំពេញទៀត ។

ដានី ៖ អូ! យើងទៅដាំដំឡូងទៀត?

ណាន់ ៖ ចាស! ដាំដំឡូង ក៏គាស់មកខ្លះមកស្ងោរហូបមក ។

ដានី ៖ គេអត់ថាអីទេ?

ណាន់ ៖ អត់ទេ គេមិនថាទេ បើយើងថា បើទៅលួចគេ កុំឲ្យតែ យើងអត់ខ្លាំងទៅលួចមានអី គេឃើញ គេវ៉ៃចោលហើយ ។

ដានី ៖ ប៉ុន្តែអឺយកដំឡូងមកស្ងោរហូបអត់អីទេ?

ណាន់ ៖ មានអី ប៉ះពេលណាទៅ គេស្នើមក គេមាន គេស្នើ គេយកមក ។

ដានី ៖ ហូបនៅផ្ទះ មិនមែនហូបនៅតាមរោងបាយទេ?

ណាន់ ៖ ចាសៗ!

ដារ៉ា ៖ អីចឹងកាលដែលនៅហ្នឹង អ៊ំនៅជាមួយគ្រួសារអ៊ំនៅជុំគ្នាទេ?

ណាន់ ៖ នៅតែជុំគ្នាចាស!

ដារ៉ា ៖ ពេលហូបចុកអីហូបជាមួយគ្នា?

ណាន់ ៖ ចាស! ហូប បើកាលណាបើមកទាន់ក៏ហូប បើកាលណាគេហូបកន្លែងវាលទៅ គេធ្វើការវាល ណោះ ។

ដារ៉ា ៖ ហើយថាក្រោយមកគ្រួសារអ៊ំស្លាប់ហ្នឹង ដឹងម៉េច?

ណាន់ ៖ ដឹងតែស្លាប់ គាត់រត់ ។

ដារ៉ា ៖ គាត់រត់ម៉េចអ៊ំ?

ណាន់ ៖ រត់គេចេញចាប់ ។

ដារ៉ា ៖ ចេញចាប់?

ណាន់ ៖ ចាស!

ដារ៉ា ៖ ចេញចាប់មូលហេតុអី?

ណាន់ ៖ មិនដឹងមូលហេតុអីណា ថាគេចាប់ទៅ គាត់ដឹងខ្លួនក៏គាត់រត់ ។

ដារ៉ា ៖ ដឹងខាងណាមកចាប់អ៊ំ?

ណាន់ ៖ ដឹងទេកាលហ្នឹងមិនដឹងពួកណាទេ ដឹងតែខាងពួកគេក្តាប់យើង មិនដឹងពួកណា ។

ដានី ៖ អ៊ំកាលហ្នឹងដូចថាអ៊ំកាលដំបូងដូចមាន តាក្រុក តាអីធ្វើប្រធានអីចឹងហ្នឹអ៊ំ?

ណាន់ ៖ ចាស!

ដានី ៖ ហើយដល់ពេលក្រោយមក តាក្រុក គេទៅណាទៅ?

ណាន់ ៖ គាត់មិនដឹងគាត់ទៅណាទេ ស្រាប់តែបាត់ខ្លួន ខ្ញុំមិនដឹងទេ ។

ដានី ៖ ហើយចុះមានអ្នកក្រោយគេមកធ្វើប្រធាន?

ណាន់ ៖ ចាស! មិនដឹងពីណាធ្វើប្រធានទៀត គេថាឈប់ គេថាខាងនិរតីៗ ។

ដានី ៖ និរតីហ្អី?

ណាន់ ៖ ចាស!

ដានី : អីចឹងប្ដីអ៊ីដែលថារត់ហ្នឹងពួកនិរតីមកធ្វើប្រធាន?

ណាន់ : ចាស! ហ្នឹងឯង ចាស! ធ្វើប្រធាន ធ្វើប្រកោយគេហ្នឹង ។

ដានី : អីចឹងបានន័យថា ពួកនិរតីគេចាប់ប្ដីអ៊ីកាលហ្នឹង?

ណាន់ : ចាសៗ!

ដានី : កាលហ្នឹងប្ដីអ៊ីគាត់ធ្វើអីបានគេចាប់?

ណាន់ : ធ្វើទំនប់ប្រឡាយនោះឯងតាមបន្ទាយនោះឯងចុះតែគេទៅតាគ្រីក តែដេញ គេទៅហើយ ។

ដានី : បាទ! អីចឹងកាលហ្នឹង និរតីដែលគេដេញហ្នឹងកាលហ្នឹងប្ដីអ៊ីគាត់ខុសអីបានគេដេញ ។

ណាន់ : គ្មានខុសអីទេ គាត់គ្មានខុសអីទេស្រាប់តែគេថាចាប់មួយទៅកើតរត់ទាំងអស់គ្នាទៅណាព្រោះខ្លាចគេវៃចោលនោះឯង ។

ដានី : គាត់រត់ទៅខាងណា?

ណាន់ : រត់ទៅដើង ។

ដានី : ទៅដើង ទៅណាទៅ?

ណាន់ : ទៅគេហៅគោកមន បេងណោះណា ។

ដានី : ខាងគោកមន ខាងបេង?

ណាន់ : ចាស! ទៅណោះ ទៅផាប់ឯណោះឯង ។

ដានី : អ៊ីដឹងថាគាត់ស្លាប់អីចឹងអត់?

ណាន់ : ដឹង ដល់យួនចូលស្រុកអី ទៅរកស៊ីបាន ខ្ញុំទៅស៊ើបសួរអី ផាប់ហើយ ផាប់ឯណោះឯង គេចាប់ដាក់គុក ។

ដានី : គេចាប់ដាក់គុក?

ណាន់ : ចាស!

ដានី : គុកនៅឯណាអ៊ី?

ណាន់ : ជាប់គុកឯឧត្តរមានជ័យ មិនដឹងគុកអី ។

ដានី : ចុះថាគេដុត?

ខេង : គេថាយួនចូល គេចាក់ប្រេងដុតយើងទៅ ។

ដានី : ដុតក្នុងឡ ឬក៏ម៉េច?

ណាន់ : មិនដឹងទេៗ ខ្ញុំនៅតែណោះ មិនដឹងទេថាប្ដីទៅហើយ ទៅក៏វាទៅមិនដុត គេចាប់បាន ។

ដានី ៖ ឆ្នាំណា អ៊ីចាំឆ្នាំទេ?

ណាន់ ៖ ខ្ញុំមិនចាំទេ មើលតែទៅ មើលបានប្រហែលមួយខែក៏យួនចូល ។

ដារ៉ា ៖ ចុះអ៊ី ចុះចំណែកអ៊ីវិញ ពេលដែលគ្រួសារអ៊ីរត់ទៅចាប់អ៊ី រត់អីចឹងទៅ?

ណាន់ ៖ គេយកខ្ញុំទៅទ្រយោង ។

ដារ៉ា ៖ អ្នកណាមកយកអ៊ីកាលហ្នឹង?

ណាន់ ៖ មិនដឹងគេណោះអ្នកធំ ខ្ញុំមិនស្គាល់គេទេណា ។

ដារ៉ា ៖ នៅឯណា?

ណាន់ ៖ មិនដឹងទេ តែពួកអ្នកចម្ងាយៗ មិនសូវដែលស្គាល់គេទេ ។

ដារ៉ា ៖ អីចឹងពេលដែលគ្រួសារអ៊ីរត់ទៅ ស្រាប់តែគេមកចាប់យកអ៊ីទៅដាក់គុក?

ណាន់ ៖ ចាស! ទៅបានប្រហែលកន្លះខែ គេយកខ្ញុំទៅទ្រយោង គេឲ្យទៅហាត់ពត់លត់ដំ បើយើងអត់មិនបានយើងទៅរកលួចអីគេ គេវ៉ៃចោលនោះឯងខ្ញុំមិនដែលហ៊ានទៅរកអីទេ ។

ដារ៉ា ៖ ចុះពេលដែលទៅកន្លែងភ្នំទ្រយោងហ្នឹងជាកន្លែងគុក ឬក៏ស្អីអ៊ី?

ណាន់ ៖ គេថាកន្លែងគុកណា ប៉ុន្តែខ្ញុំមិនដែលឃើញគុកគេមិនដឹងគុកគេត្រង់ណា ពួកស្រីៗគេដាក់ដូចថាគុកគេធ្វើរោងវែងទៅអ៊ីចេះគេឲ្យដេកទៅ ប្រុសៗគេដាក់ផ្សេង មិនដឹងជាគុកគេយ៉ាងម៉េច ។

ដារ៉ា ៖ អីចឹង?

ណាន់ ៖ ចាស!

ដារ៉ា ៖ ចុះកូនអ៊ីអត់ទៅជាមួយទេពេលហ្នឹង?

ណាន់ ៖ ដេកជាមួយខ្ញុំ ។

ដារ៉ា ៖ ទៅជាមួយដែរ?

ណាន់ ៖ ចាស! ចុះកូនវាតូចណោះ ។

ដារ៉ា ៖ កាលហ្នឹងអាយុប៉ុន្មានឆ្នាំ?

ណាន់ ៖ នៅត្រឹមប៉ុណ្ណេះ ។

ដានី ៖ ប៉ុនណា?

ណាន់ ៖ នេះ ប៉ុណ្ណេះ ។

ដានី ៖ ប៉ុននេះ អាយុប៉ុន្មានកាលហ្នឹង?

ណាន់ ៖ មិនដឹងអាយុប៉ុន្មានទេ មើលសព្វថ្ងៃវាប៉ុន្មានទេនេះ ។

ដានី ៖ ប៉ុនណាកាលហ្នឹង?

ណាន់ ៖ សួរកូនចាំខ្លះដែរ ខ្ញុំវាមិនចាំទេ អានេះកូនទេ តែខ្ញុំនេះមិនដឹងទេ។

ដារ៉ា ៖ ចុះពេលចូលទៅដល់កន្លែងភ្នំទ្រយោងហ្នឹង គេឲ្យអី?

ណាន់ ៖ គេឲ្យខ្ញុំកាប់ទន្រ្ទានខែត្រ ធ្វើដី ច្រូតនោះឯង។

ដារ៉ា ៖ មានជាទារុណកម្ម មានជាអីទេ អត់មានគេវ៉ៃធ្វើបានទេ?

ណាន់ ៖ ទេ បើយើងទៅលួចគេ បានគេវ៉ៃ ខ្ញុំមិនដែលទៅលួចអីនរណា ស៊ីតែអត់ កូនខ្ញុំនិយាយថ្នា ទោស ពងក្ដក៏ហើម ស៊ីតែអត់ មិនដែលហ៊ានទៅលួចរបស់នរណាទេ។

ដានី ៖ ចុះអ៊ីពេលដែលអ៊ីដឹងថាទៅដល់កន្លែងទ្រយោងហ្នឹងថា ពូដូចថានៅកន្លែងភ្នំទ្រយោងហ្នឹង កន្លែងមន្ទីរសន្តិសុខទ្រយោងហ្នឹងណា គេបែងចែកអីយ៉ាងម៉េច ដូចថា?

ណាន់ ៖ គេឲ្យតែបបរ។

ដានី ៖ ប៉ុន្តែអ្នកដែលនៅក្នុងហ្នឹង អ្នកនៅក្នុងហ្នឹងដូចថាភាគច្រើនគេចេញឲ្យទៅធ្វើការ ឬក៏មានអ្នកដែលគេត្រូវដាក់គុក ដាក់ខ្នោះដាក់អីដែរ?

ណាន់ ៖ ចុះវាមិនដែលឃើញទេណា អីចេះណា មិនដែលឃើញគេទេ ប្រុសៗគេដាក់ផ្សេង មិនដែលដឹង។

ខេង ៖ ប្រុសៗគេឲ្យវ៉ៃថ្ម។

ណាន់ ៖ កូនខ្ញុំ វាចាំបានខ្លះ អាល័យតែទៅ ទៅតែតាមគេ។

ដារ៉ា ៖ ចុះបង កាលហ្នឹងបងទៅជាមួយម្ដាយជាប់នៅហ្នឹងដែរ?

ណាន់ ៖ ចាស ហ្នឹងឯង!

ដារ៉ា ៖ ហើយអាចរត់លេង អាចអីបានទេពេលហ្នឹង?

ខេង ៖ ធ្វើ នេះធ្វើការ ក៏ធ្វើទៅ។

ណាន់ ៖ វាធ្វើការបានអី។

ដារ៉ា ៖ ចុះបងធ្វើការបានដែរពេលហ្នឹង?

ខេង ៖ ធ្វើបានតើ ទៅកាប់ទន្រ្ទានខែត្រ។

ណាន់ ៖ កាប់ទន្រ្ទានខែត្រ។

ដានី ៖ អាយុប៉ុន្មានកាលហ្នឹង?

ខេង ៖ ខ្ញុំអាយុប្រហែលជាង១០។

ណាន់ ៖ ជាង១០ឆ្នាំដែរ ជាង១០។

ខេង :    ខ្ញុំអាចនៅចាំបានខ្លះៗ ។

ណាន់ :    វាចាំបាននោះ ។

ដារ៉ា :    ចុះពេលសម្រាន្តអី សម្រាន្តជាមួយម្ដាយជាប់គ្នា?

ខេង :    ជាមួយម៉ែ ។

ណាន់ :    ចាស! វាចាំបានខ្លះនោះឯង ។

ខេង :    ស្រីៗគេឲ្យនៅផ្សេងទៅ ប្រុសៗយុវជនតែគេពេញវ័យណាគេដាក់ផ្សេង.... ។

ណាន់ :    ដាច់ពីខ្ញុំមិនដែលឃើញគេនោះ ។

ដារ៉ា :    ចុះបងកាលទៅកាប់ទន្រ្ទានខែត្រ ទន្រ្ទានអីចឹងមានជួបឃើញមនុស្សប្រុសជាប់ខ្នោះ ជាប់អីដែរទេ?

ខេង :    ឃើញខ្លះដែរ ប៉ុន្តែនៅតូច ឃើញគេដាក់ខ្នោះនោះ ប៉ុន្តែខ្នោះនោះខ្នោះឈើ ប៉ុន្តែមិនដឹងថាទោសហ្នឹងកម្រិតយ៉ាងម៉េច ។

ដានី :    ខ្នោះហ្នឹងដាក់យ៉ាងម៉េច របៀបម៉េច?

ខេង :    ខ្នោះឈើពីរ ចោះក្រវិលដាក់ជើង ។

ណាន់ :    វាក្មេង វាដើរឃើញ មិនដូចឯងមនុស្សចាស់មិនហ៊ានដើរទេខ្លាច ។

ខេង :    ចង់សួរ ពួកយុវជន គាត់បួស ឈ្មោះ លោក ថង ។

ណាន់ :    គាត់ឈឺហើយ គាត់ឈឺ ។ ឈឺនេះហ្នឹងណា នៅផ្ទះនេះឯង នៅវត្ត ។

ដារ៉ា :    ហើយកាលបងជាប់ជាមួយនឹងម្ដាយហ្នឹង ជាប់នៅហ្នឹងមានក្មេងៗដូចបងច្រើនទេ?

ខេង :    មានច្រើនខ្លះដែរ ក្មេងប្រុស ក្មេងស្រី ប៉ុន្តែគេឲ្យកាប់ទន្រ្ទានខែត្រ...ទៅជាមួយពួកចាស់ៗតូចៗគេឲ្យនៅជុំម្ដាយហ្នឹងកាប់ទន្រ្ទានខែត្រទៅលីចុះពីលើភ្នំ ខ្ញុំចាំ លីអាចម៍គោដាក់ធ្វើជី ។

ដារ៉ា :    អីចឹងមានក្មេងច្រើនដែរនៅជាមួយ?

ខេង :    មាន ។

ណាន់ :    មាន ច្រើនទៅតាមម្ដាយ ។

ដារ៉ា :    ហើយមានអ្នកណាគ្រប់គ្រងកុមារក្មេងៗអស់ហ្នឹង?

ខេង :    អត់មានទេ ទៅឃ្វាលគោ ពួកឈ្លបគេ គេដើរមើល ។

ណាន់ :    អត់មានទេ ។

ដារ៉ា :    អីចឹងពេលម្ដាយទៅណា ទៅតាមអីចឹងទៅ?

ខេង :    បាទ! ដល់ពេលទៅច្រូត យើងអត់ចេះច្រូតទេ យើងជួរធ្វើជី ។

ណាន់ ៈ ចិញ្ចាំជី ខ្ញុំទៅច្រូត ។

ខេង ៈ ទៅច្រូតផ្សេងទៅ ។

ដារ៉ា ៈ ចុះពេលដែលហូបចុកអី?

ខេង ៈ ហូបចុក បើរបបហូប ដល់ពេលគាត់ទៅច្រូត គាត់ទៅហូបណោះ ខ្ញុំបើករបបហូបនេះ ។ ។

ណាន់ ៈ នៅឯណោះ ឯលែងនេះ ។

ដារ៉ា ៈ នៅត្រង់រោងហ្នឹង?

ខេង ៈ បាទ!

ដារ៉ា ៈ ចុះបងបានធ្លាប់ឮឈ្មោះសន្តិសុខណាខ្លះទេ អាចចាំទេ?

ខេង ៈ ឮតែឈ្មោះ មិនដែលឃើញ ។

ណាន់ ៈ មិនដែលឃើញ ។

ដារ៉ា ៈ ឈ្មោះអីខ្លះ?

ខេង ៈ មេគុកហ្នឹងឈ្មោះ តាសឿន ។

ដារ៉ា ៈ មេគុកនោះឈ្មោះ តាសឿន ហើយឮតែ តាសឿន មួយឬមានអ្នកណាផ្សេងទៀត បងធ្លាប់?

ខេង ៈ ឮតែ តាសឿន ទេ ខ្ញុំមិនដែលស្គាល់ទេ ។

ណាន់ ៈ ឮតែដូចថា យាយ ចែម យាម ចែម មិនដែលស្គាល់ទេ ។

ដារ៉ា ៈ អីចឹងបងដែលឮឈ្មោះ យាយចែម ដែរកាលដែលអឺជាប់?

ណាន់ ៈ ឮ មិនដែលឃើញមុខ ។

ដានី ៈ ឮថា យាយចែម ហ្នឹង ថា យាយចែម ហ្នឹងធ្វើអីទៅ?

ខេង ៈ មិនដឹងទេ ចៅហ្វាយស្រុកទេដឹង ។

ណាន់ ៈ ស្អីបើមិនដែលដឹង ។

ដារ៉ា ៈ តែៗឮ ឧទាហរណ៍អម្បាញ់មិញបងថាឮថាឈ្មោះ សឿន ហ្នឹងជាប្រធាននៅហ្នឹង កន្លែងគុក ហ្នឹងណា គ្រប់គ្រង ហើយអត់ដែលឃើញមុខទេ?

ណាន់ ៈ មិនដែលឃើញទេ មិនដឹងគេទៅច្រកណាទេកន្លែងណា ។

ដារ៉ា ៈ ហើយ យាយចែម ដែលឃើញមុខទេ?

ខេង ៈ មិនដែលទេ គាត់នៅខាងណោះ មិនដែលឃើញរូបរាងគាត់យ៉ាងម៉េច ឮតែឈ្មោះ ។

ណាន់ ៈ បានតែសួរអ្នកភ្នំលៀប ។

ដារ៉ា : បាទ! កន្លែងភ្នំលៀប និងមកន្លែងគុកភ្នំ?

ណាន់ : គុកភ្នំទ្រយោងនោះបៀតគ្នា ។

ខេង : អត់ឆ្ងាយ ប្រហែលមួយគីឡូជាងទេបង ភ្នំលៀបអីចេះ ភ្នំទ្រយោងបត់ទៅអីចេះ ។

ដារ៉ា : អីចឹងបងអត់ដែលចេញទៅខាងក្រៅ?

ណាន់ : មិនហ៊ានចេញ ។

ខេង : ខ្ញុំលួចមកផ្ទះម្ដង ។

ណាន់ : វាធំគ្រាន់ហើយ ។

ខេង : ខ្ញុំដើរមក ប្រធានគេសួរថា ទៅណា? ខ្ញុំថាបើកអង្ករ គ្មានមនុស្សដើរទេនេះ មានតែទាហាន គេថាទៅបើកអង្ករឯណា? ខ្ញុំថាបើកទៅ... ដល់លើកក្រោយ អ្នកភូមិខ្ញុំនេះគេទៅ ធ្វើស្រែនៅអូរលៀប ។ ២២.៣៨

ដារ៉ា : មកដល់ផ្ទះទេ?

ខេង : ផ្ទះនៅភូមិត្រពាំងវែង នៅកន្លែងភូមិបង ឆាំង យុ ។

ដារ៉ា : ហើយដល់ពេលមកដើរកាត់តាមផ្លូវហ្នឹង អត់ឃើញមានស្ថានភាពអីម៉េចដែរបង?

ខេង : អត់មានទេបងស្ងាត់ជ្រាប មានតែយោធាគេនៅតាមស្ពានមួយៗ តែខ្ញុំកូនក្មេងវាមិនសូវចាប់ អារម្មណ៍ទេកុហកវាអីចឹង ។

ណាន់ : បើមនុស្សចាស់វាតាមជាប់ៗ បើចាប់បាន ។

ខេង : ហើយនៅក្នុងនោះក៏មិនដឹងថា ខ្ញុំមកៗ ។

ដារ៉ា : នៅអាកន្លែងភ្នំទ្រយោងហ្នឹងបងពេលយប់ព្រលប់អីមានភ្លើងមានអីដែរទេ?

ខេង : អត់មានអ្នកណាហ៊ានទៅ អត់មានទេ ។

ណាន់ : ទេ ស្ងាត់ជ្រាប ។

ដារ៉ា : ហើយមានការស្នាក់នៅអី គេងអីចឹងមានមុងមានអីដែរទេ?

ខេង : មានមុងខ្លួនឯង ។

ណាន់ : មានមុងតែខ្លួនឯង ដែលយកទៅណានាង ។

ដារ៉ា : នៅចងបានដែរ?

ខេង : បាទ!

ដារ៉ា : ហើយបងដើរកាប់ទន្រ្ទានខែត្រ
កាប់អីច្រើនមកធ្វើដីហ្នឹងដែលប្រទះឃើញកន្លែងណាគេសម្លាប់ មនុស្ស ឬកន្លែងណា?

ណាន់ ៖ មិនដែលឃើញ គេមិនដែលឲ្យយើងដឹងទេ ។

ដារ៉ា ៖ ចុះបងដែលឮ រស់នៅហ្នឹងដែលដូចថាឮជាសំឡេងស្រែក សំឡេងអី?

ខេង ៖ អត់មានទេ ប៉ុន្តែបើគេយកទៅវៃចោល គេយកទៅវៃចោលណោះ គេមិនដែលយកទៅវៃចោលឲ្យឃើញទេ អ្នកណាដែលខុស យប់ស្ងាត់ជ្រាបដូចថា មានប៉ុស្តិ៍គេយាមមួយៗជុំវិញ អ្នកណាហ៊ានដើរ ។

ណាន់ ៖ ហ៊ានចេញអី ។

ដារ៉ា ៖ ចុះពេលបងជាប់នៅកន្លែងហ្នឹងបងមានអារម្មណ៍ថាជា ដូចរបៀបថាជាជាប់គុក ឬយ៉ាងម៉េចបង?

ខេង ៖ អត់មានដូចថាគេជាប់គុកទេ ព្រោះកន្លែងគេយកទៅកសាងបើយើងទៅលួចគេវៃចោលទៅ មិនដឹងធ្វើម៉េច ។

ណាន់ ៖ ធ្វើបាប ។

ខេង ៖ មានមនុស្សៗរត់ទៅ ។

ណាន់ ៖ មានមនុស្សរត់ គេចាប់បានយកវៃចោលទៅ ។

ដារ៉ា ៖ មានមនុស្សរត់ដែរ?

ណាន់ ៖ មាន ។

ខេង ៖ មានមនុស្សរត់ពីភូមិ រត់ទៅបាត់ រត់មានសេរីភាព ។

ណាន់ ៖ តែចេញពីកន្លែងគេនោះហើយក៏រត់ យើងនៅដើងភ្នំ ។

ខេង ៖ ដាក់ខ្នោះមាន ប៉ុន្តែមិនដឹងថាគេធ្វើយ៉ាងម៉េចទេ ខ្ញុំមិនបានដឹង ។

ដារ៉ា ៖ ប៉ុន្តែគ្រាន់ឃើញមានដាក់ខ្នោះដាក់អីដែរ?

ខេង ៖ មានៗ ដាក់ខ្នោះ ។

ដារ៉ា ៖ អាដាក់ខ្នោះហ្នឹង នៅវាដេកនៅអីជិតបងដែរឬ?

ខេង ៖ ពេលខ្ញុំដើរទៅបើកបបរហ្នឹង ខ្ញុំឃើញគេធ្វើរោងជិតធ្វើរោងទទឹងថ្ងៃអីចេះ ដូចថាឃើញតែជើងគេធ្វើសំយ៉ាបអីចេះទៅ គេដាក់អន្ទុយទល់មុខគ្នា ធ្វើប្រឡោះអីចេះទៅ ដាក់ជើងមួយទៅ ខាងណោះក៏មើលមកខាងណោះ ខ្ញុំមិនបានឃើញច្រើនទេ ដឹងតែមានមនុស្សដេក ។

ដារ៉ា ៖ បងបានឃើញញឹកញាប់ទេអ្នកទោសជាប់?

ខេង ៖ ឃើញ ប៉ុន្តែយូរៗមិនដឹងទៅណា ។

ណាន់ ៖ មិនដឹងមនុស្សទៅណាបាត់ យើងមិនដឹងគេវៃចោល មិនដឹងថាអី អីចេះបានថា ។

ដានី ៖ បើតាមបងប៉ាន់ស្មានមើល អ្នកដែលធ្វើការនៅត្រង់កន្លែងភ្នំទ្រយោងហ្នឹង?

ណាន់ ៖ វាច្រើនណាស់ឯង ច្រើន ប៉ុន្តែថា ដូចគេថាបាត់ ចេះតែបាត់ៗ ស្លាត់មនុស្ស មិនដឹងគេយកទៅណាមិនដឹងទេ ។

ខេង ៖ វាអត់ឲ្យដើរវាវរកមើលទេ ឧបមាថាកងកុមារទៅកាប់ទន្រ្ទានខែត្រ មួយកន្លែងប៉ុន្មានម៉ុំទៅច្រើនតែវៃថ្មី បន្ទុះប្រុសៗវៃថ្មភ្នំទ្រយោង ។

ណាន់ ៖ ខ្ញុំនោះគេមកសួរមុនខ្ញុំមិនដែលដឹងថា ប្រុសៗវៃថ្ម ខ្ញុំមិនដែលដឹងទេ គេសួរមុនណា ខ្ញុំមិនដឹងទេ ឲ្យសួរកូននេះបានប្រាប់គេ ខ្ញុំមិនដឹងទេ ។

ដារ៉ា ៖ បងមិញ អឺគាត់ប្រាប់ឈ្មោះដែរតែ អ្ហឹបងឈ្មោះអីមិញ?

ខេង ៖ ខ្ញុំឈ្មោះ ខេង ។

ដារ៉ា ៖ ស្អី ខេង បង?

ខេង ៖ រិន ខេង ។

ដារ៉ា ៖ រិន ខេង! ហើយបងអាយុប៉ុន្មានឆ្នាំហើយឥឡូវហ្នឹង?

ខេង ៖ សព្វថ្ងៃហ្នឹងខ្ញុំ សែប៉ុន្មានហើយ ៤៦ ។

ដានី ៖ ឆ្នាំអីគេ?

ខេង ៖ ឆ្នាំមមី ។

ដារ៉ា ៖ ឆ្នាំមមី! ហើយបងធ្វើការអីដែររាល់ថ្ងៃ?

ណាន់ ៖ មានធ្វើអី ។

ខេង ៖ មានធ្វើអីទេ ។

ដារ៉ា ៖ រកស៊ីធម្មតា?

ណាន់ ៖ ធ្វើស្រែ ។

ខេង ៖ ធ្វើស្រែ ។

ដារ៉ា ៖ អូ! បាទ ។

ដានី ៖ ប្រពន្ធបងឈ្មោះអីដែរ?

ណាន់ ៖ នេះគ្នាឈ្មោះ ដានី ។

ខេង ៖ ឈ្មោះ ដានី ។

ដារ៉ា ៖ ឈ្មោះ ដានី ។ ហើយអឺកាលពីដែលគេមកជួបមានអ្នកណាខ្លះ អឺអ្នកណាខ្លះ មានខ្មែរយើងមានបរទេសអីដែរ?

ណាន់ ៖ ចាស! មានខ្មែរ បរទេស ។

ខេង ៖ ទេ ដួបយប់នោះណ៎ា! ។

ដារ៉ា ៖ អត់ទេ ។ ពេលដែលហៅទៅសួរណាអឺ?

ណាន់ ៖ មុខដូចបារាំង ។

ដារ៉ា ៖ ដូចបារាំង?

ណាន់ ៖ ចាស!

ដារ៉ា ៖ ហើយសួរអឺច្រើនទេ ។

ណាន់ ៖ ចា! គេសួរ មិនច្រើនប៉ុន្មានទេ ព្រោះខ្ញុំមិនឃើញមានអី ។ ខ្ញុំមិនដឹងចាស! សួរថាដូចថា មានគេឃាម ខ្ញុំថាមាននោះឯង គេឃាមដូចថាណេះមួយ នោះមួយទៅណា ។ គេសួរថា នៅត្រង់ណានោះ ខ្ញុំថានៅជើងភ្នំ ចង្កេះភ្នំ ហើយគេចេះតែកត់ ។

ដារ៉ា ៖ អ្ហឺ! ម៉េចបានគេដឹងថាអឺជាប់នៅភ្នំទ្រយោង?

ណាន់ ៖ ចុះមានគេអ្នកប្រាប់ ។

ដារ៉ា ៖ អ្នកណាអ្នកប្រាប់អឺ?

ណាន់ ៖ មិនដឹងទេ ស្រាប់តែមកសួររកខ្ញុំ ។

ដារ៉ា ៖ សួររកអឺ?

ណាន់ ៖ សួររកខ្ញុំទៅ ហៅខ្ញុំ ក៏ខ្ញុំឆ្លើយដូចខ្ញុំមិនដែលដឹង ។ ដូចកូនថា មានគុកមានអី ។ គេសួរដែរថា ចុះឃើញគុក មានគុក អានាងអើយដឹងគុកយ៉ាងណា វាមិនឃើញ ។

ខេង ៖ គេមិនសួរឲ្យដើររហោតរហូតទេ ខ្ញុំទៅបើកបបរទៅ ។

ណាន់ ៖ វាមិនឃើញ ឃើញតែធ្វើរោងឲ្យខ្ញុំដេកចេះ ក៏គ្នាដេករដែតចេះទៅ ទាំងកូនទាំងម៉ែទៅ ។ ភ្លឺទៅ គេថាឲ្យទៅច្រូត ក៏ទៅ ប៉ុន្តែថាឲ្យទៅកើបដីក៏ទៅចឹងណ៎ា ។

ដារ៉ា ៖ ចឹងកាលហ្នឹងអ្ហឺ គេមានអ្ហឺខាងអ្នកធ្វើការនៅកន្លែងភ្នំទ្រយោងដែលហៅអឺទៅសួរនាំអីទេ?

ណាន់ ៖ អត់ទេ មិនដែលសោះ ។

ដារ៉ា ៖ ពីរឿងគ្រួសារអឺអីយ៉ាងម៉េចៗ អត់ទេ?

ណាន់ ៖ ទេ មិនដែលហៅទេ ។

ដារ៉ា ៖ មានតែទៅធ្វើការធម្មតា?

ណាន់ ៖ ចាស!

ខេង ៖ ពេលថាច្រូត គិតពីច្រូត ។

ណាន់ : ហ៊ីឲ្យទៅប្រូតក៏ទៅប្រូតទៅ ។

ដារ៉ា : ចុះខាងថាគេមកសួរអ៊ីប៉ុន្មាននាក់នោះណា សួរកាលហ្នឹង មានបានសួរបង កូនអីទេ?

ណាន់ : ទេ អត់ទេ មិនបានសួរទេ ។

ដារ៉ា : អត់បានសួរទេ?

ណាន់ : ចាស! សួរខ្ញុំអីនោះ បើខ្ញុំមិនសូវដឹងអី បើវារាប់ឃើញស៊ីៗ ហើយខ្ញុំដែលឃើញណា ។

ដានី : ហើយក្រៅពីអ៊ី មានគេសួរពីណាទៀត?

ណាន់ : មិនដឹងទេ គេសួរមនុស្សពីរនាក់ពីដែរណា ប៉ុន្តែគេថាមិនដែលដឹងដែរ សួរ ។

ដានី : សួរពីណា?

ខេង : អ្នកស្រុកប៉ោយសំរោង ។

ណាន់ : អ្នកស្រុកប៉ោយសំរោង ។

ដានី : ឈ្មោះអី ឈ្មោះអីគេ?

ណាន់ : ឈ្មោះ មិនដឹងឈ្មោះនាងអីទេ សម្លាស ។

ខេង : គាត់ជាប់ដែរណ៎ា!

ណាន់ : ទេគេនៅតែឯណោះ គេមិនបានជាប់ដល់សួរ គេសួរថាខ្ញុំមិនដឹងអីទេ ។ វាកូនចៅកូនអី ខ្ញុំមិនដឹងវាទេថាចេះ ។

ខេង : អ្នកទៅជាប់គុកទួលយោងអត់មានគានៅក្នុងភូមិយើងនេះទេណា គ្រប់ស្រុក តាំងពីបេង គោកមន នោះ ផ្អែកសន្តិសុខគេយក ។

ដានី : អ៊ីចឹងអ៊ីជាប់គុកហ្នឹងរហូតដល់ពេលណាបានចេញ?

ខេង : វៀតណាមចូល ។

ណាន់ : វៀតណាម ឃើញអីចេះ សូរសន្ធឹកឡានគគឹកមកក៏ផ្អើលនាំគ្នារត់ គេរត់ព្រុគគឹក ។ខ្ញុំគេរត់ អីចេះ ផ្អើលព្រុគគឹក ដល់ស្តាប់ៗ ទៅក៏ ។

ខេង : គេប្រកាសមេក្រូអាកូនមេក្រូតូចនោះណា បងប្អូននៅភូមិណា ឲ្យអញ្ជើញទៅតាមភូមិនោះ វិញក៏នាំគ្នាមក ។

ណាន់ : ក៏រត់មក ព្រុគគឹក ។

ខេង : ពេញថ្នល់គុក ។

ណាន់ : ឆ្ងាយណាស់អានាង ។

ដារ៉ា : អ៊ីចឹងកាលហ្នឹង អាប្រធានគុកហ្នឹងទៅណា តាសឿន ហ្នឹង?

ខេង :	ដឹងគេទៅណា ។

ណាន់ :	ដឹងគេទៅណាអស់ ។

ខេង :	គេដឹង ។

ណាន់ :	គេដឹង តែយើងមិនដឹងគេដងអានាង ។

ដាវ៉ា :	អ្ហឺ!

ណាន់ :	ស្រាប់តែឡើងថ្ងៃទៅ ពួឡានមកគគុក ។

ដាវ៉ា :	ចុះមានសល់អ្នកទោសអីនៅហ្នឹងទេពេលយើងរត់ទៅ?

ណាន់ :	មិនមានទេ មិនមានទេ ។

ខេង :	ចេញមកអស់ ។

ណាន់ :	ចេញអស់ ។

ខេង :	អត់មាននរណានៅដែលដាក់គុកដាក់អី អត់មានទេ ទៅអស់ ។

ដានី :	ចុះអ្នកជាប់ខ្នោះ?

ខេង :	ជាប់ខ្នោះដឹងគេយកទៅណា ។

ណាន់ :	ដឹងយកទៅណាអស់ ដែលអ្នកជាប់ខ្នោះយើងមិនដឹងទេ ។

ដានី :	ចុះអ្ហឹបង ពេលហ្នឹងពេលមានគេទៅប្រជុំ គេទៅដូចថាទៅ ពេលដែលបងនៅក្នុងហ្នឹង គេមាន ចូលទៅប្រជុំអីដែរអត់?

ខេង :	ទេខាងខ្ញុំ ។

ណាន់ :	ប្រជុំ ។

ខេង :	កុមារអីចឹងមិនដែលទេ បើមនុស្សចាស់គេហៅ ។

ណាន់ :	គេហៅដែលមនុស្សចាស់អី ក៏គេហៅប្រជុំទៅធ្វើការ គេប្រាប់ថាធ្វើការគេនិយាយអីចេះៗ ទៅណា ។

ដានី :	ពីណាគេអ្នកមកប្រជុំហ្នឹង?

ណាន់ :	ទេគាហ្នឹងនោះ ក្នុងគុកនោះហើយ យើងមិនដែលស្គាល់គេទេ មិនដែលស្គាល់ ។ ពួកគេអ្នកក្តាប់យើង ។

ដានី :	អ្នកក្តាប់ហ្នឹងឈ្មោះអីទៅអឹមានស្គាល់ឈ្មោះគាត់ទេ?

ណាន់ :	ពួកឈ្លបនោះ មានអ្នកណាស្គាល់គេទេ ។

ដានី ៖ មានដែលឮឈ្មោះដូចជាឈ្មោះ សឿន អីហ្នឹងគាត់ទៅហៅអ្នកទោសមកប្រជុំ មកដាក់ផែនការទេ?

ណាន់ ៖ ខ្ញុំមិនដែលឃើញទេ។

ដានី ៖ មិនដែលឃើញទេ?

ណាន់ ៖ ចាស!

ដានី ៖ ចុះបងមានដែល?

ខេង ៖ អត់ទេ ខ្ញុំកុមារគេមិនដែលសួរហៅទេ។

ណាន់ ៖ គេដែលហៅ ដែលខ្ញុំនេះក៏ដូចរូបគា សឿន នោះ ខ្ញុំស្គាល់នេះឯង។ ប៉ុនគាត់មិនដែល ខ្ញុំមិន ឃើញគាត់ទៅធ្វើការមិនដែលឃើញៗហៅថា អឺ! ធ្វើការអីចេះអីណា មិនឃើញទេ។

ដានី ៖ ចោះអត់ដែលឃើញមុខ យាយ ចែម ទេ?

ណាន់ ៖ អូ! អត់ដែលឃើញទេអានាង ឮតែគេថាយាយ ចែមៗ។

ដានី ៖ អ៊ីចឹង បង អ៊ឹ ខ្ញុំដូចជាអស់សំណួរអីត្រូវសួរនាំទៀតហើយ អ៊ីចឹងអ៊ឹបុក៏បងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំមិនបានសួរនាំទេ?

ខេង ៖ មានអីបង។

ដានី ៖ ចុះអ៊ឹមានអីចង់បន្ថែម?

ណាន់ ៖ មិនមានអីទេអានាង ខ្ញុំកាន់តែយ៉ាប់ជាងកូន។

ដានី ៖ បាទអ៊ីចឹងខ្ញុំអរគុណច្រើនអ៊ឹ បងខ្ញុំអរគុណច្រើន។

«ចប់»